# ច្បាប់ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** គោលបំណង

ច្បាប់នេះកំណត់អំពីនីតិវិធីនៃការពិន័យស៊ីវិល ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ដែលចែងអំពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ។

**មាត្រា ២.-** ការអនុវត្តជាសកល

បញ្ញត្តិនៃច្បាប់ដែលចែងអំពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះនីតិវិធីនៃការពិន័យស៊ីវិល លើកលែងតែករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់នេះ ។

## ជំពូកទី ២
## សមត្ថកិច្ច

**មាត្រា ៣.-** សមត្ថកិច្ច

រឿងក្តីពិន័យស៊ីវិល ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលបានកំណត់ នៅក្នុងមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់ទៅ តាមលំនៅឋាន ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី របស់ភាគីនៃនីតិវិធីនៃការពិន័យស៊ីវិលនោះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ផ្សេង ។

## ជំពូកទី ៣
## នីតិវិធី

**មាត្រា ៤.-** ការចាប់ផ្តើមនីតិវិធី

នីតិវិធីនៃការពិន័យស៊ីវិល ត្រូវចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់តុលាការ ។

**មាត្រា ៥.–** នីតិវិធីនៃការវិនិច្ឆ័យអំពីការពិន័យស៊ីវិល

១-ការសម្រេចសេចក្តីអំពីការពិន័យស៊ីវិល ត្រូវធ្វើឡើងដោយដីកាសម្រេច ។

២-ដីកាសម្រេចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ដោយមានសំអាងហេតុ និង សេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើលិខិតដីកាសម្រេចនេះ ។

៣-ដើម្បីចេញដីកាសម្រេចអំពីការពិន័យស៊ីវិល តុលាការត្រូវសួរមតិយោបល់ពីតំណាងអយ្យការ និង ស្តាប់សេចក្តីថ្លែងការណ៍របស់ភាគី ជាមុន ។

៤-ចំពោះដីកាសម្រេចអំពីការពិន័យស៊ីវិល តំណាងអយ្យការ និង ភាគីអាចប្តឹងជំទាស់បាន ។ ដីកាសម្រេចដាក់ពិន័យស៊ីវិល មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

៥-ក្នុងករណីដែលបានចេញដីកាសម្រេចដាក់ពិន័យស៊ីវិល ប្រាក់ប្រដាប់ក្តីតុលាការ ដែលចាំបាច់សម្រាប់នីតិវិធីនៃដីកាសម្រេចអំពីការពិន័យស៊ីវិល រួមទាំងនីតិវិធីនៃការវិនិច្ឆ័យអំពីបណ្តឹងជំទាស់ គឺជាបន្ទុករបស់បុគ្គលដែលទទួលដីកាសម្រេចនោះ ហើយក្រៅពីករណីនេះ គឺជាបន្ទុករបស់រដ្ឋ ។

៦-ក្នុងករណីដែលមានបណ្តឹងជំទាស់ពីភាគី ចំពោះដីកាសម្រេចដាក់ពិន័យស៊ីវិល ប្រសិនបើតុលាការនៃបណ្តឹងជំទាស់ លុបចោលនូវដីកាសម្រេចដើម ហើយចេញដីកាសម្រេចថ្មីអំពីការពិន័យស៊ីវិល ទោះបីជាដីកាសម្រេចនេះ ជាដីកាសម្រេចដាក់ពិន័យស៊ីវិលក៏ដោយ ក៏ប្រាក់ប្រដាប់ក្តីតុលាការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ គឺជាបន្ទុករបស់រដ្ឋដែរ ។

**មាត្រា ៦.–** ការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល

១-ដីកាសម្រេចដាក់ពិន័យស៊ីវិល ត្រូវអនុវត្តដោយការបង្គាប់របស់តំណាងអយ្យការ ។ ការបង្គាប់នេះមានអានុភាពដូចគ្នានឹងលិខិតអនុវត្តដែលមានរូបមន្តអនុវត្ត ។

២-ការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល ត្រូវធ្វើដោយអនុលោមតាមគន្ថីទី ៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេងទៀតស្តីពីនីតិវិធីនៃការអនុវត្តដោយបង្ខំ ប៉ុន្តែ មិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេច មុនពេលអនុវត្តឡើយ ។

៣-ប្រសិនបើយល់ឃើញថាចាំបាច់ ដើម្បីធ្វើការអនុវត្តដីកាសម្រេចដាក់ពិន័យស៊ីវិល តំណាងអយ្យការអាចសួរទៅស្ថាប័នរដ្ឋ ឬ អង្គភាពសាធារណៈ ឬ អង្គភាពឯកជនឱ្យធ្វើរបាយការណ៍អំពីចំណុចដែលចាំបាច់បាន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៧.-** ការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។